ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ : ១៤០៧ PC.អក

# សេចក្ដីជូនដំណឹង

## ស្ដីពីការ ផ្អាកការផ្សព្វផ្សាយលក់ និងផ្អាកបើកឯកសារដេញថ្លៃ/ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត គ្រប់គម្រោង

**យោង** ៖ សេចក្ដីសម្រេចលេខ : ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញនិងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទិញនិងមានបំណងទិញឯកសារដេញថ្លៃ/ពិគ្រោះថ្លៃប្រកួតប្រជែងជាសាធារណៈ និងបានទទួលឯកសារដេញថ្លៃមានកម្រិត ឲ្យបានជ្រាបថា ៖ ដើម្បីចូលរួមអនុវត្តតាមសេចក្ដីសម្រេចលេខ : ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញនិងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ អគ្គិសនីកម្ពុជា បានសម្រេចផ្អាកការផ្សព្វផ្សាយលក់ឯកសារដេញថ្លៃ/ពិគ្រោះថ្លៃដែលបាននឹងកំពុងផ្សព្វផ្សាយនៅក្នុង Website : www.edc.com.kh និង Page របស់កាសែតរស្មីកម្ពុជា និងផ្អាកការបើកឯកសារដេញថ្លៃ/ពិគ្រោះថ្លៃនិងដេញថ្លៃមានកម្រិត គ្រប់គម្រោងទាំងអស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការប្រកាសជូនដំណឹងសារជាថ្មី ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី ជ្រាបជាព័ត៌មាន តាមការគួរ ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ ចេត្រ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០២១
ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហាច់ ឡុច

**ចម្លងជូន:**
- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដើម្បីជូន "ជ្រាប"
- -គ្រប់នាយកដ្ឋានជំនាញ
- -វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី
- -នាយកដ្ឋានមូលនិធិអគ្គិសនីការូនីយកម្មជនបទ ជូន "ជាព័ត៌មាន"